អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍

ទីភ្នាក់ងារទេសន្តប្រវេសន៍ អង្គការសហប្រជាជាតិ

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-May-2021, 16:32
CMS/CFO: Ly Bunloung

# ពិធីសារ និងវិធានការការពារជំងឺកូវីត១៩

## ប្រវត្តិ៖

នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ លោកស្រី Kristin Parco អ្នកសម្របសម្រួលអង្គការសហប្រជាជាតិ សម្រាប់ជំងឺកូវីត១៩, ប្រធានបេសកកម្ម អង្គការអន្តរជាតិទេសន្តរប្រវេសន៍ កម្ពុជា បណ្ឌិត Kim Lee (មន្ត្រីសម្របសម្រួលផ្នែកវេជ្ជសាស្ត្រ អង្គការសហប្រជាជាតិ), បណ្ឌិត Karman Gurung អ្នកសម្របសម្រួលប្រព័ន្ធការពារកម្រិតដំបូង (First line of defence coordinator) នៃអង្គការអន្តរជាតិទេសន្តរប្រវេសន៍ កម្ពុជា បានធ្វើទស្សនកិច្ចនៅបរិវេណ អ.វ.ត.ក ដើម្បីត្រួតពិនិត្យ និងផ្តល់អនុសាសន៍ និងមតិយោបល់ ពាក់ព័ន្ធនឹងវិធានការគ្រប់គ្រង និងការពារការឆ្លងរាតត្បាត ដើម្បីដំណើរការសវនាការតុលាការដោយសុវត្ថិភាព។ អ្នកសម្របសម្រួល ប្រព័ន្ធការពារកម្រិតដំបូង នៃអង្គការអន្តរជាតិទេសន្តរប្រវេសន៍ បានផ្តល់នូវសេវាកម្មនានាយ៉ាងសកម្ម ទៅបុគ្គលិកអង្គការសហប្រជាជាតិ និងអ្នកនៅក្នុងបន្ទុករបស់ពួកគេ នៅក្នុងប្រទេសកម្ពុជា រួមមានការតាមដានសុខភាពតាមប្រព័ន្ធសោតទស្សន៍ ចំពោះបុគ្គលិក និងអ្នកនៅក្នុងបន្ទុក ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ការតាមដានតាមប្រព័ន្ធសោតទស្សន៍ ចំពោះករណីជំងឺកូវីត១៩ ក្នុងពេលស្នាក់នៅមន្ទីរពេទ្យ ការប្រឹក្សាតាមសោតទស្សន៍ នៅមុនពេល អំឡុងពេល និងក្រោយពេលចាក់វ៉ាក់សាំង និងសេវាសុខាភិបាលជាច្រើនដទៃផ្សេងទៀត ក្នុងអំឡុងពេលរីករាលដាលនេះ។

ភាគច្រើននៃវិធានការការពារ ត្រូវបានកំណត់និងរៀបចំផែនការបានល្អ។ អង្គការអន្តរជាតិទេសន្តរប្រវេសន៍ សូមផ្តល់នូវអនុសាសន៍បន្ថែមមួយចំនួន ដើម្បីដំណើរការសវនាការតុលាការឱ្យបានរលូន៖

***<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>***៖ មុនពេលចូលក្នុងបរិវេណ

១. កម្រងសំណួរត្រួតពិនិត្យ ជាតារាងត្រួតពិនិត្យ សម្រាប់គ្រប់គ្នា។ ប្រសិនបើមានចំណុចណាមួយឆ្លើយ បាទ/ចាស ចាំបាច់ត្រូវផ្ទៀងផ្ទាត់ ដើម្បីទទួលបានព័ត៌មានបន្ថែម។

អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍

ទីភ្នាក់ងារទេសន្តប្រវេសន៍ អង្គការសហប្រជាជាតិ

២. បន្ថែមពីលើការវាស់កំដៅ និងស្កេន QR code ការពាក់ម៉ាស់ (គឺម៉ាស់វះកាត់ ឬម៉ាស N95, ម៉ាស់មានប្រហោងខ្យល់ មិនត្រូវអនុញ្ញាតឡើយ)។ របាំងមុខ សម្រាប់អ្នកដែលត្រូវនិយាយយូរ ទឹកលាងសម្អាតដៃ សម្រាប់អ្នកដែលចូលក្នុងបរិវេណ អ.វ.ត.ក ព្រមទាំងក្រុមត្រួតពិនិត្យរបស់ អ.វ.ត.ក។

**នៅក្នុងសាលសវនាការ (នៅក្នុងបរិវេណសាលបិទជិតដោយកញ្ចក់)**

**ក. នៅក្នុងបន្ទប់សវនាការ (សាលកញ្ចក់)**

. **បន្ថយចំនួនមនុស្ស៖** សម្រាប់តែបុគ្គលិកសំខាន់ៗ (ប្រហែល២០ ទៅ៣០នាក់ ជាបុគ្គលិកសន្តិសុខ គ្រប់គ្រងតុលាការ និងតុលាការ) ដែលត្រូវមានវត្តមាន នៅក្នុងសាលកញ្ចក់។ ជាការប្រសើរដែលពួកគេ មិនត្រូវផ្លាស់ប្តូរវេនឡើយ សម្រាប់កិច្ចដំណើរការនីតិវិធី រយៈពេលប្រាំថ្ងៃ។

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ យ៉ាងច្រើនបំផុត៣០នាក់ ដែលរួមមានតែបុគ្គលសំខាន់ៗប៉ុណ្ណោះ។ ជាអនុសាសន៍ គឺត្រូវរក្សាបុគ្គលិកដដែល សម្រាប់រយៈពេលប្រាំថ្ងៃ ដើម្បីបង្កើតជារបាំងពពុះ នៅក្នុងចំណោមបុគ្គលិកសំខាន់តែ ៣០នាក់ ដដែលនេះ។**

. **ការត្រួតពិនិត្យ៖** សន្តិសុខត្រូវត្រួតពិនិត្យ ការចេញចូល ហើយត្រូវមានច្រកបែងចែក ដើម្បីការពារកុំឲ្យមានការប្រមូលផ្តុំ។

**<u>អនុសាសន៍របស់ អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ បុគ្គលិកសន្តិសុខត្រូវត្រួតពិនិត្យពីចម្ងាយ ជាប្រចាំ ទៅលើមនុស្សទាំងអស់ ដើម្បីធានាថាមិនមានការទម្លាក់ម៉ាស់ចុះក្រោយច្រមុះ ឬព្យួរម៉ាស់។ ចាំបាច់ត្រូវមានការរំលឹកជាទៀងទាត់ លើកលែងតែអ្នកដែលត្រូវនិយាយយូរ ប៉ុន្តែចាំបាច់ត្រូវតែបន្តពាក់របាំងមុខ ប្រសិនបើត្រូវដោះម៉ាស់។**

. **ម៉ាស់៖** ត្រូវទិញទៅតាមបទដ្ឋាន របស់អង្គការសុខភាពពិភពលោក ត្រូវពាក់ជាប់រហូត ចំពោះអ្នកដែលមានវត្តមាន នៅពេលមិនត្រូវការនិយាយ (សូមមើលខាងក្រោម)។

អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍

ទីភ្នាក់ងារទេសន្តប្រវេសន៍ អង្គការសហប្រជាជាតិ

**<u>អនុសាសន៍របស់ អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ម៉ាស់វះកាត់ ឬម៉ាស N95 ។ ម៉ាស់មានប្រហោងខ្យល់ មិនត្រូវបានអនុញ្ញាតឡើយ។**

. **ការលាងសម្អាតដៃជាកាតព្វកិច្ច នៅពេលចូល** សម្រាប់គ្រប់គ្នា។ អាល់កុលលាងសម្អាតដៃ ត្រូវផ្តល់ជូននៅតាមកន្លែងអង្គុយនីមួយៗ។

**<u>អនុសាសន៍របស់ អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ បន្ថែមពីលើនេះ ក្រដាសផ្សព្វផ្សាយទំហំ A4 ណែនាំពីការប្រើប្រាស់ម៉ាស់គ្រប់ពេល ការរក្សាគម្លាតសង្គម និងការប្រើប្រាស់អាល់កុលលាងដៃញឹកញាប់ ត្រូវបិទនៅលើតុ។ ការបង្ហាញជារូបភាព គឺជាការរំលឹកជាប្រចាំ ឲ្យមនុស្សអនុវត្តតាម។**

. **តម្រងម៉ាស៊ីនត្រជាក់៖** ត្រូវផ្លាស់ប្តូរជារៀងរាល់ថ្ងៃ ឬជាជម្រើសផ្សេង ត្រូវបាញ់ថ្នាំសម្លាប់មេរោគ។

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ត្រូវផ្លាស់ប្តូរជារៀងរាល់ថ្ងៃ**

. **ទ្វារ៖** ត្រូវបើក។

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ទ្វារទាំងពីរត្រូវបើក ដើម្បីឲ្យមានខ្យល់ចេញចូល។**

. **ការសម្លាប់មេរោគដោយអាល់កុល ឬសារធាតុគីមី៖** ធ្វើជារៀងរាល់ថ្ងៃ ឬក្នុងពេលសម្រាកសវនាការតាមអនុសាសន៍។

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ក្នុងពេលសម្រាក២០នាទី សម្រាប់វគ្គនីមួយៗ និងក្នុងពេលសម្រាកអាហារថ្ងៃត្រង់។ ការសម្លាប់មេរោគដោយអាល់កុល ដែលត្រូវប្រើប្រាស់ជាការបាញ់សម្រាប់ការសម្អាតបន្ថែមទៀត ទៅលើបរិវេណនានា។ ចាំបាច់ត្រូវបង្រៀនមនុស្សឱ្យចេះបាញ់សម្លាប់មេរោគដោយត្រឹមត្រូវ។ មានរូបភាពនៃឧបករណ៍បាញ់ ដែលភ្ជាប់មកជាមួយ ដែលអាចរកទិញបានដោយងាយស្រួលនៅតាមទីផ្សារ។**

. **ចៅក្រម៖** ប្រាំមួយរូប មានអាយុពី៥១ឆ្នាំ ដល់៧៨ ឆ្នាំ ដែលត្រូវមានវត្តមាន។

អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍

ទីភ្នាក់ងារទេសន្តប្រវេសន៍ អង្គការសហប្រជាជាតិ

- ចៅក្រមអន្តរជាតិ/មន្ត្រីអង្គការសហប្រជាជាតិ

- ចៅក្រមជាតិ

- របាំងកញ្ចក់កម្ពស់៨០ស.ម ត្រូវដាក់នៅពីមុខអាសនៈ

- **<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ គួរតែមានកញ្ចក់បីជ្រុង ដាច់ពីគ្នា ដើម្បីផ្តល់សុវត្ថិភាពដល់ចៅក្រម**

- ការរៀបចំជាបទដ្ឋាន ដែលមានចៅក្រម៧រូប មានន័យថា មានចន្លោះប្រហែល១.៥ម ពីគ្នា ហើយចន្លោះនេះកាន់តែធំ ដោយសារតែចៅក្រមមួយរូបអវត្តមាន។

  **<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ គម្លាត ១.៥ ម ពីគ្នា។**

- ចៅក្រមត្រូវអង្គុយនៅពេលនិយាយ

  **<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ដោយសារតែត្រូវដោះម៉ាស់ ជាអនុសាសន៍ ត្រូវប្រើប្រាស់របាំងមុខ ដោយសារតែជាការការពារបន្ថែមមួយជាន់ទៀត ហើយត្រូវប្រើប្រាស់ដោយមនុស្សតែម្នាក់រហូត ហើយអាចសម្លាប់មេរោគដោយឧបករណ៍សម្លាប់មេរោគធម្មតា ឬបាញ់អាកុល។ មានរូបភាពគម្រូ ដែលភ្ជាប់មកជាមួយ ដែលអាចរកទិញបានដោយងាយស្រួល នៅតាមទីផ្សារ។**

. **ក្រឡាបញ្ជី និងបុគ្គលិកតុលាការ** (អង្គុយនៅមុខចៅក្រម)

- ចំនួនអតិបរិមាបួននាក់ គម្លាតពីគ្នា ១.៤៦ ដល់ ១.៨ម

- ត្រូវដាក់របាំងកញ្ចក់កម្ពស់៥០ស.ម ខណ្ឌពួកគេ

- ក្រឡាបញ្ជីមួយរូបត្រូវឡើងឈរនិយាយ

អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍

ទីភ្នាក់ងារទេសន្តប្រវេសន៍ អង្គការសហប្រជាជាតិ

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ត្រូវប្រើប្រាស់របាំងមុខ ប្រសិនបើដោះម៉ាស់ នៅពេលដែលនិយាយ។ គម្លាតពីគ្នាគឺ១.៥ម។**

. **ភាគី៖** ភាគីចំនួនបីត្រូវចូលរួម (មានសហមេធាវីពីររូប ក្នុងមួយភាគី)

- ត្រូវដាក់របាំងកញ្ចក់កម្ពស់ ១២០ស.ម នៅពីមុខកន្លែងអង្គុយរបស់វាគ្មិនម្នាក់ៗ។ កម្ពស់នេះគឺគិតដល់ការដែលត្រូវឈរ នៅពេលនិយាយ។

- មានគម្លាតប្រហែល១.៦ម ពីអ្នកតំណាងផ្លូវច្បាប់នីមួយៗ នៅពេលអង្គុយ។

- ភាគីប្រហែលត្រូវនិយាយរយៈពេលវែង ការប្រើប្រាស់ម៉ាស់ អាចត្រូវអនុវត្តតាមអនុសាសន៍

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ប្រសិនបើដោះម៉ាស់រយៈពេលយូរដើម្បីនិយាយ គួរតែពាក់របាំងមុខ។**

. **ជនជាប់ចោទ**៖

- ជាបុរសវ័យ៩១ឆ្នាំ មានជម្ងឺប្រចាំកាយ ហើយមិនទាន់បានចាក់វ៉ាក់សាំង។ នីតិវិធីជាទូទៅគឺ ត្រូវនាំជនជាប់ចោទ ចូលក្នុងសាលសវនាការ ដើម្បីអង្គុយនៅក្រោយមេធាវីការពារក្តី។ ប្រសិនបើគាត់មិនអាចតាមដានកិច្ចដំណើរការនីតិវិធី (ដោយសារសុខភាព បញ្ហាមិនស្រួលខ្លួន ឬអស់កម្លាំង) គាត់អាច៖

- ត្រូវបានប្រធានអង្គជំនុំជម្រះ អនុញ្ញាតឱ្យត្រឡប់ទៅបន្ទប់ឃុំឃាំង នៅជាន់ក្រោម ដើម្បីតាមដានកិច្ចដំណើរការនីតិវិធី។

- ត្រូវដាក់របាំងកញ្ចក់កម្ពស់១២០ស.ម ដែលអាចលើកដាក់បាន ប្រសិនបើជនជាប់ចោទត្រូវបានតម្រូវឱ្យចូលក្នុងសាលសវនាការ។

អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍

ទីភ្នាក់ងារទេសន្តប្រវេសន៍ អង្គការសហប្រជាជាតិ

- ត្រូវមានការអនុម័តយល់ព្រម៖ ជនជាប់ចោទមិនគួរនាំយកមកក្នុងសាលសវនាការឡើយ។
- ប្រសិនបើជនជាប់ចោទ ត្រូវមានវត្តមាន បុគ្គលពេទ្យ សន្តិសុខនិងអ្នកលើកត្រូវពាក់សម្លៀកបំពាក់ការពារ និងស្រោមដៃជាដើម ហើយជនជាប់ចោទក៏ត្រូវពាក់ដូចគ្នា។

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ដើម្បីឲ្យជនជាប់ចោទ អាចមានវត្តមានយ៉ាងយូរបំផុត ១៥នាទី ដើម្បីបង្ហាញខ្លួនដល់ចៅក្រម និងអាស្រ័យទៅលើស្ថានភាពសុខភាពរបស់គាត់។ មន្ត្រីសុខាភិបាលដែលមានភារកិច្ច ប្រចាំការជាមួយជនជាប់ចោទ ត្រូវពិនិត្យមើលស្ថានភាពសុខភាព នៅតាមបណ្តាថ្ងៃដែលមានសវនាការ។**

. ជំនួយការច្បាប់៖ ត្រូវអង្គុយនៅកៅអី ក្រោយអ្នកតំណាងភាគី (ត្រឹមពីរនាក់ក្នុងមួយភាគី)

- ត្រូវដាក់របាំងកញ្ចក់ កម្ពស់៥០ស.ម ខណ្ឌពួកគេ។
- គម្លាតប្រហែលជា១.៦ ទៅ១.៧ម។
- បើចាំបាច់ ជំនួយការច្បាប់អាចអង្គុយពីជួរ ក្រោយវាគ្មិន ដើម្បីធានានូវគម្លាតសមស្រប។

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ប្រសិនបើមានវិធានការពាក់ម៉ាស់ វិធានការខាងលើគឺសមស្រប។**

**. រង្វង់ក្រចកសេះ និងកន្លែងសាក្សី**

- ត្រូវដាក់របាំងកញ្ចក់ កម្ពស់១២០ស.ម នៅពីខាងមុខ។

. រយៈពេលកិច្ចដំណើរការនីតិវិធី ពីដំបូងគ្រោងរយៈពេល៥ថ្ងៃ ប៉ុន្តែប្រហែលត្រូវកាត់បន្ថយ មកត្រឹម៣ទៅ៤ថ្ងៃ អាស្រ័យលើភាពស្មុគ្រស្មាញ។

- មានបួនវគ្គ ដែលមានរយៈពេលពី៤៥នាទី ទៅ១ម៉ោង៣០នាទី។

អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍

ទីភ្នាក់ងារទេសន្តប្រវេសន៍ អង្គការសហប្រជាជាតិ

- ការឈប់សម្រាករយៈពេលខ្លីពីរដង នៅចន្លោះវគ្គទី១ និងទី២ និងវគ្គទី៣ និងទី៤៖ មានរយៈពេល២០នាទី។

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ការបាញ់សម្លាប់មេរោគ ក្នុងពេលសម្រាក**

- ការឈប់សម្រាកអាហារថ្ងៃត្រង់៖ ២ម៉ោង

**<u>អនុសាសន៍របស់ អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ បាញ់សម្លាប់មោរោគ ក្នុងពេលឈប់សម្រាក**

. ការផ្លាស់ទីក្នុងសាលសវនាការ៖ ធ្វើឡើងតែនៅពេលចូល និងចេញជាផ្លូវការ នៅពេលចាប់ផ្តើម និងបញ្ចប់វគ្គ។ ប្រសិនបើចៅក្រមត្រូវប្រជុំពិភាក្សាសម្រេចក្នុងវគ្គ អ្នកបកប្រែមួយរូប (ដែលត្រូវអង្គុយនៅក្បែរអាសនៈ ហើយត្រូវមានគម្លាតសមស្រប ក្នុងពេលដែលមិនមានតម្រូវការ) នឹងត្រូវហៅមកសម្របសម្រួល។

**ខ. នៅក្នុងសាលសាធារណៈ**

. **បន្ថយចំនួន៖** កន្លែងអង្គុយសម្រាប់មនុស្សប្រមាណ៤០០ ទៅ៤៥០នាក់ ត្រូវបន្ថយមកត្រឹម៥០នាក់។

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ការបន្ថយចំនួនមកត្រឹម ៥០នាក់ គឺជាការសមស្រប ប្រសិនបើការនេះត្រូវបានអនុញ្ញាត ដោយរាជរដ្ឋាភិបាល ស្តីពីការគោរពតាមវិធានសុខាភិបាលសាធារណៈ។ ត្រូវដាក់ផ្លាកហាមអង្គុយ ឬសញ្ញាខ្វែង នៅកន្លែងដែលហាមអង្គុយ ដើម្បីឲ្យមើលឃើញដោយផ្ទាល់ (មានភ្ជាប់មកជាមួយនូវផ្លាកសញ្ញា)**

. **ការលាងដៃ និងការសម្លាប់មេរោគដែលចាំបាច់៖** នៅមុនពេលចូល

អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍

ទីភ្នាក់ងារទេសន្តប្រវេសន៍ អង្គការសហប្រជាជាតិ

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ផ្ទាំងផ្សព្វផ្សាយទំហំ A4 ដែលមានវិធានការពារការពារ គឺពាក់ម៉ាស់ រក្សាគម្លាតសង្គម និងលាងដៃឲ្យបានញឹកញាប់ ត្រូវបិទនៅក្នុងសាលសាធារណៈ (ផ្ទាំងគំរូមានភ្ជាប់មកជាមួយ)**

. **នីតិវិធីសឹក**៖ នឹងត្រូវអនុវត្តដោយសន្តិសុខ ដើម្បីទប់ស្កាត់ការប្រមូលផ្តុំ

. **គម្លាត**៖ យ៉ាងហោច១.៥ម ពីម្នាក់ទៅម្នាក់

. **តម្រងម៉ាស៊ីនត្រជាក់**៖ ត្រូវផ្លាស់ប្តូររាល់ថ្ងៃ ឬជាជម្រើសផ្សេងទៀត ត្រូវសម្លាប់មេរោគ

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ត្រូវផ្លាស់ប្តូររាល់ថ្ងៃ។**

**ទ្វារ**៖ ត្រូវបើក

. **ការសម្លាប់មេរោគដោយអាល់កុល/សារធាតុគីមី**៖ ត្រូវធ្វើឡើងតាមការចាំបាច់ និងនៅពេលដែលចាំបាច់ (ចន្លោះពីវគ្គមួយទៅវគ្គមួយ ជារៀងរាល់ថ្ងៃ ជាដើម) **<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ នៅពេលសម្រាក**

**គ. ខាងក្រៅសាលសវនាការ**

. **បន្ទប់ពិភាក្សាសម្រេច (សម្រាប់ចៅក្រម)** ស្ថិតនៅក្រោយអាសនៈ ដែលត្រូវប្រើប្រាស់ក្នុងពេលសម្រាក និងសម្រាប់ការពិភាក្សាសម្រេច តាមការចាំបាច់

- **រឹតបណ្តឹងការចេញចូល**៖ សម្រាប់តែចៅក្រម ជំនួយការច្បាប់ ដែលមានសន្តិសុខត្រួតពិនិត្យវត្តមាន
- **វិធានការគម្លាត និងពាក់ម៉ាស់** ត្រូវដាក់ឲ្យអនុវត្ត
- **សម្ភារៈអនាម័យ** ត្រូវមាន (កន្លែងលាងដៃ សាប៊ូ អាល់កុលលាងដៃ)

អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍

ទីភ្នាក់ងារទេសន្តប្រវេសន៍ អង្គការសហប្រជាជាតិ

. **កន្លែងដទៃ** ដូចជា ផ្លូវដើរ ជាទីកន្លែងរីតបណ្តឹង គឺមានបុគ្គលិកសន្តិសុខ និងបុគ្គលិកគ្រប់គ្រងតុលាការ ដែលមានកាតព្វកិច្ចពាក់ម៉ាស់ និងលាងសម្អាតដៃនៅពេលចូល។ បរិវេណគឺមានភាពទូលាយ។

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ផ្ទាំងផ្សព្វផ្សាយទំហំ A4 ដែលមានវិធានការ៣ ការពារ គឺពាក់ម៉ាស់ រក្សាគម្លាតសង្គម និងលាងដៃឲ្យបានញឹកញាប់ ត្រូវដាក់បង្ហាញ ជាការក្រើនរំលឹក ជាប្រចាំ។**

. **បន្ទប់ឃុំឃាំង៖** ត្រូវសម្លាប់មេរោគរាល់ថ្ងៃ និងនីតិវិធីជាធរមានដទៃទៀត របស់អគ្គនាយកដ្ឋាន ពន្ធនាគារ។

ត្រូវមានការអនុម័តយល់ព្រម៖ ជនជាប់ចោទគួររក្សានៅមន្ទីរឃុំឃាំង ជាជាងដឹកជញ្ជូនទៅសាល សវនាការ។ ការនេះកាត់បន្ថយជាអតិបរមា នូវការទាក់ទងជាមួយភ្នាក់ងារចម្លងណាមួយ។

**<u>អនុសាសន៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍</u>៖ ប្រសិនបើអាច ត្រូវជៀសវាងទាំងស្រុង ប៉ុន្តែ ប្រសិនបើជនជាប់ចោទចាំបាច់ត្រូវមានវត្តមានដោយផ្ទាល់ មន្ត្រីសុខាភិបាលត្រូវវាយតម្លៃលើស្ថានភាព សុខភាពរបស់ជនជាប់ចោទមុនពេលមកដល់ និងមានវត្តមានយ៉ាងច្រើនបំផុតរយៈពេល១៥នាទី។**

**<u>អនុសាសន៍ដទៃទៀត</u>**

ពិធីសារនិងវិធានការការពាររបស់ អ.វ.ត.ក ត្រូវបានកំណត់យ៉ាងល្អ ដោយមានការវាស់កម្តៅ ពិធីសា សម្រាប់អ្នកចូលក្នុងបរិវេណ រួមទាំងសាលសវនាការ។ អនុសាសន៍បន្ថែម ត្រូវបានផ្តល់ដើម្បីគោរព តាមបទដ្ឋានគ្រប់គ្រងការពារការឆ្លងរាតត្បាត ដើម្បីធានានូវសុវត្ថិភាពប្រជាជន ក្នុងអំឡុងពេលកិច្ច ដំណើរការនីតិវិធី។

ប្រសិនបើគោរពតាមវិធានការទាំងអស់ខាងលើ កិច្ចដំណើរការនីតិវិធីតុលាការ អាចចាប់ផ្តើមនៅប៉ុន្មាន ថ្ងៃខាងមុខ រួមទាំងការអនុម័តយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការដំណើរការ ដែលមានមនុស្ស

អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍

ទីភ្នាក់ងារទេសន្តប្រវេសន៍ អង្គការសហប្រជាជាតិ

យ៉ាងច្រើនបំផុត ៣០នាក់ នៅក្នុងបន្ទប់តែមួយ។ បើមិនដូច្នេះទេ ចាំបាច់ត្រូវមានការកែសម្រួល ទៅលើចំនួនមនុស្សនៅក្នុងសាលសវនាការតែមួយ។

**<u>កំណត់សម្គាល់៖ អនុសាសន៍សម្រាប់ការរៀបចំការសម្លាប់មេរោគ</u>**

. ទឹកអូសាវ៉ែល ២៥០ ម.ល លាយទឹក ២០ ល

. ការបាញ់អាល់កុលកម្រិត ៧០ ឡើង

**របាយការណ៍រៀបចំដោយ**

**បណ្ឌិត Karman Gurung /បណ្ឌិត Kim Lee**

មន្ត្រីសុខាភិបាលទេសន្តប្រវេសន៍/មន្ត្រីសម្របសម្រួលសុខាភិបាលអង្គការសហប្រជាជាតិនៅកម្ពុជា

**របាយការណ៍ពិនិត្យនិងអនុម័តដោយ**

**លោកស្រី Kristin Parco**

អ្នកសម្របសម្រួលការរីករាលដាលជំងឺកូវីត១៩ របស់អង្គការសហប្រជាជាតិនៅកម្ពុជា